ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

នស/រកត/១០២៤/១៣០៩

# ព្រះរាជក្រឹត្យ
# ស្តីពី
# គោរមងារឧកញ៉ា

មាតិកា

២០២៤

# មាតិកា


| ព្រះរាជក្រឹត្យលេខ នស/រកត/១២២៤/១៣០៩ ស្ដីពី គោរមងារឧកញ៉ា |
| --- |
| ជំពូកទី១ បទប្បញ្ញត្តិទូទៅ<br>(មាត្រា១ដល់មាត្រា៣) |
| ជំពូកទី២ ស្ថាប័នមានសមត្ថកិច្ច<br>(មាត្រា៤ដល់មាត្រា៦) |
| ជំពូកទី៣ លំដាប់ថ្នាក់នៃគោរមងារឧកញ៉ា<br>(មាត្រា៧) |
| ជំពូកទី៤ លក្ខខណ្ឌនិងលក្ខណសម្បត្តិដែលត្រូវផ្ដល់គោរមងារឧកញ៉ា<br>(មាត្រា៨ដល់មាត្រា១០) |
| ជំពូកទី៥ ការវាយតម្លៃផ្ដល់គោរមងារឧកញ៉ា<br>(មាត្រា១១ដល់មាត្រា១២) |
| ជំពូកទី៦ ឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់<br>(មាត្រា១៣) |
| ជំពូកទី៧ សមាគមឧកញ៉ាកម្ពុជា<br>(មាត្រា១៤ដល់មាត្រា១៥) |
| ជំពូកទី៨ សិទ្ធិ និងកាតព្វកិច្ចរបស់លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា<br>(មាត្រា១៦ដល់មាត្រា១៧) |
| ជំពូកទី៩ ការបញ្ចប់គោរមងារឧកញ៉ា<br>(មាត្រា១៨) |
| ជំពូកទី១០ អន្តរប្បញ្ញត្តិ<br>(មាត្រា១៩) |
| ជំពូកទី១១ អវសានប្បញ្ញត្តិ<br>(មាត្រា២០ដល់មាត្រា២១) |


<u>**ប្រភពឯកសារ**</u>

ទាញយកចេញពីឆាណែលតេលេក្រាមសម្ដេចធិបតីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៤ ម៉ោង ៩ និង៤៨នាទី

https://t.me/Dr_Hunmanetofcambodia/209571

# ព្រះរាជក្រឹត្យ

នស/រកត/១០២៤/១៣០៩

## ស្ដីពី

## គោរមងាឧកញ៉ា

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ព្រះរាជក្រឹត្យនេះកំណត់អំពីគោលការណ៍ លក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការផ្តល់គោរមងារឧកញ៉ា ជាការលើកទឹកចិត្តដល់រូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរ ដែលមានគុណសម្បត្តិ ស្នាដៃ និងគុណបំណាច់ធំធេងក្នុងការចូលរួមអភិវឌ្ឍ និងកសាងជាតិ ព្រមទាំងការគ្រប់គ្រង និងការបញ្ចប់គោរមងារឧកញ៉ា ដើម្បីធានាបាននូវគុណតម្លៃ សេចក្ដីថ្លៃថ្នូរ ទំនៀមទម្លាប់ ប្រពៃណីល្អ សណ្ដាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា២ .-**

ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរដែលទទួលបានគោរមងារឧកញ៉ា នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងព្រះរាជក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចតទៅ៖

- គោរមងារឧកញ៉ា សំដៅដល់ងារកិត្តិយសដែលព្រះមហាក្សត្រទ្រង់ព្រះរាជទានដោយព្រះរាជក្រឹត្យទៅតាមលំដាប់ថ្នាក់ ដល់រូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរដែលមានគុណសម្បត្តិ ស្នាដៃ និងគុណបំណាច់ធំធេងក្នុងការចូលរួមអភិវឌ្ឍនិងកសាងជាតិ
- គោរមវន្ត សំដៅដល់រូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរដែលទទួលបានគោរមងារឧកញ៉ាដោយព្រះរាជក្រឹត្យ។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងពិនិត្យនិងវាយតម្លៃលើសំណើសុំគោរមងារនិងការបញ្ចប់គោរមងារឧកញ៉ា ដែលសរសេរជាអក្សរកាត់ថា **គ.ព.ឧ.គ.** មានសមត្ថកិច្ចពិនិត្យ វាយតម្លៃ និងលើកយោបល់ជូននាយករដ្ឋមន្ត្រីលើសំណើសុំផ្តល់និងបញ្ចប់គោរមងារឧកញ៉ា។

**គ.ព.ឧ.គ.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | អនុប្រធានប្រចាំការ |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ១រូប | សមាជិក |
| - តំណាងសមាគមឧកញ៉ាកម្ពុជា ២រូប | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានឥស្សរិយយសនិងគោរមងារ | លេខាធិការ។ |

សមាសភាពជាក់ស្តែងនៃ **គ.ព.ឧ.គ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៥ .-**

**គ.ព.ឧ.គ.** មានអគ្គនាយកដ្ឋានឥស្សរិយយសនិងគោរមងារនៃទីស្តីការគណៈរដ្ឋមន្ត្រី ជាលេខាធិការដ្ឋានក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន។



www.moj.gov.kh

**មាត្រា៦ .-**

ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិប្រោសព្រះរាជទានគោរមងារឧកញ៉ាដល់រូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរ ដែលមានគុណសម្បត្តិ ស្នាដៃ និងគុណបំណាច់ធំធេងក្នុងបុព្វហេតុជាតិ សាសនា ព្រះមហាក្សត្រ។

នាយករដ្ឋមន្ត្រីតែម្នាក់គត់ មានសិទ្ធិលើកសំណើទូលថ្វាយព្រះមហាក្សត្រក្នុងការស្នើសុំគោរមងារឧកញ៉ា និងការបញ្ចប់គោរមងារឧកញ៉ា។

## ជំពូកទី៣
## លំដាប់ថ្នាក់នៃគោរមងារឧកញ៉ា

**មាត្រា៧ .-**

គោរមងារឧកញ៉ាមាន ៣(បី)លំដាប់ថ្នាក់ ដូចខាងក្រោម៖

- លំដាប់ថ្នាក់ទី១ លោកអ្នកឧកញ៉ា
- លំដាប់ថ្នាក់ទី២ អ្នកឧកញ៉ា
- លំដាប់ថ្នាក់ទី៣ ឧកញ៉ា។

## ជំពូកទី៤
## លក្ខខណ្ឌនិងលក្ខណសម្បត្តិដែលត្រូវផ្តល់គោរមងារឧកញ៉ា

**មាត្រា៨ .-**

គោរមងារឧកញ៉ាលំដាប់ថ្នាក់ណាមួយដូចមានចែងក្នុងមាត្រា៧នៃព្រះរាជក្រឹត្យនេះ ត្រូវផ្តល់ជូនរូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរ ដោយផ្អែកតាមគុណសម្បត្តិ ស្នាដៃ និងគុណបំណាច់ធំធេងដែលបានចូលរួមអភិវឌ្ឍ និងកសាងជាតិ។

គុណសម្បត្តិ ស្នាដៃ និងគុណបំណាច់ក្នុងការចូលរួមអភិវឌ្ឍ និងកសាងជាតិ មានជាអាទិ៍ ការចូលរួមបរិច្ចាគធនធានជាថវិកា ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬសម្ភារបរិក្ខារនានាសម្រាប់កិច្ចការសង្គមនិងការងារមនុស្សធម៌ផ្សេងៗ ឬការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា ក្នុងនោះមានដូចជា ផ្លូវ ស្ពាន សាលារៀន មន្ទីរពេទ្យ ប្រព័ន្ធធារាសាស្ត្រ វត្តអារាម អគារសាធារណៈជាដើម ព្រមទាំងរបកគំហើញនូវបច្ចេកវិទ្យាថ្មីៗណាមួយ ឬស្នាដៃពិសេសដែលមានអត្ថប្រយោជន៍សម្រាប់សង្គមជាតិ។

ទំហំទឹកប្រាក់នៃការចូលរួមបរិច្ចាគធនធានឬសម្ភារបរិក្ខារនានា ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា ឬរបកគំហើញនូវបច្ចេកវិទ្យាថ្មីៗណាមួយ ឬស្នាដៃពិសេសដែលមានអត្ថប្រយោជន៍សម្រាប់សង្គមជាតិខាងលើ ដែលជាកម្មវត្ថុនៃការផ្តល់គោរមងារឧកញ៉ាតាមលំដាប់ថ្នាក់ណាមួយ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៩ .-**

ក្រៅពីលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៨នៃព្រះរាជក្រឹត្យនេះ រូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរដែលត្រូវផ្តល់គោរមងារឧកញ៉ា ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានប្រវត្តិរូបច្បាស់លាស់
- មានកិរិយាមារយាទល្អ
- ពុំធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ
- ប្រកបមុខរបរស្របច្បាប់។



www.moj.gov.kh

**មាត្រា១០.-**

គោរមងារឧកញ៉ាមានវិសមិតភាពជាមួយមុខងារជាមន្ត្រីនគរបាលជាតិ និងយោធិន ដែលកំពុងបំពេញការងារតាមក្រសួង ស្ថាប័ននានារបស់រដ្ឋ លើកលែងតែគោរមវន្តដែលមានចំណេះជំនាញពិសេសលើវិស័យណាមួយ ហើយមានការទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចជាតិឬអន្តរជាតិ។

## ជំពូកទី៥
## ការវាយតម្លៃផ្តល់គោរមងារឧកញ៉ា

**មាត្រា១១.-**

គោរមងារឧកញ៉ាតាមលំដាប់ថ្នាក់ ត្រូវផ្តល់ជូនរូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានសេចក្តីស្នើសុំពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ផ្អែកតាមយោបល់ពិនិត្យនិងវាយតម្លៃរបស់ **គ.ព.ទ.គ.** ដោយអនុលោមតាមមាត្រា៨ និងមាត្រា៩ នៃព្រះរាជក្រឹត្យនេះ។

ក្នុងករណីចាំបាច់ នាយករដ្ឋមន្ត្រីអាចលើកសំណើទូលថ្វាយព្រះមហាក្សត្រក្នុងការស្នើសុំគោរមងារឧកញ៉ាតាមលំដាប់ថ្នាក់ណាមួយ។

**មាត្រា១២.-**

គ្រប់ក្រសួង ស្ថាប័ន និងសមាគមឧកញ៉ាកម្ពុជា ដែលមានបំណងស្នើសុំគោរមងារឧកញ៉ាជូនរូបវន្តបុគ្គលដែលបានចូលរួមអភិវឌ្ឍនិងកសាងជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ត្រូវពិនិត្យនិងវាយតម្លៃគុណសម្បត្តិស្នាដៃ និងគុណបំណាច់របស់រូបវន្តបុគ្គលនោះ ផ្អែកតាមលក្ខខណ្ឌ និងលក្ខណសម្បត្តិ ដូចមានចែងក្នុងមាត្រា៨ មាត្រា៩ និងមាត្រា១១ នៃព្រះរាជក្រឹត្យនេះ រួចលើកសំណើជូនទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងសុំការសម្រេចពីនាយករដ្ឋមន្ត្រី។

បែបបទនិងនីតិវិធីនៃការស្នើសុំនិងវាយតម្លៃក្នុងការផ្តល់គោរមងារឧកញ៉ា ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦
## ឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

**មាត្រា១៣.-**

គោរមវន្តដែលទទួលបានគោរមងារជាលោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា មានឯកសណ្ឋានសញ្ញាសក្តិ និងសញ្ញាសម្គាល់ សម្រាប់ប្រើប្រាស់ក្នុងពេលចូលរួមពិធីបុណ្យជាតិ ពិធីបុណ្យប្រពៃណីជាតិ និងពិធីផ្លូវការផ្សេងៗ ដែលត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៧
## សមាគមឧកញ៉ាកម្ពុជា

**មាត្រា១៤.-**

សមាគមឧកញ៉ាកម្ពុជាដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានទទួលស្គាល់ជាដៃគូរបស់រាជរដ្ឋាភិបាលលើការងារដូចខាងក្រោម៖

- ជាស្ថាប័នតែមួយគត់ដែលតំណាងឱ្យគោរមវន្តទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



www.moj.gov.kh

- ជួយរាជរដ្ឋាភិបាលលើការពិនិត្យនិងវាយតម្លៃចំពោះសំណើសុំផ្តល់គោរមងារឧកញ៉ាតាមលំដាប់ថ្នាក់ ស្របតាមព្រះរាជក្រឹត្យនេះ
- ជួយរាជរដ្ឋាភិបាលលើការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ និងរៀបចំឯកសណ្ឋានផ្លូវការរបស់គោរមវន្ត ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងធ្វើរបាយការណ៍បច្ចុប្បន្នភាពមក **គ.ព.ទ.គ.**
- ជួយរាជរដ្ឋាភិបាលលើការពិនិត្យសំណើសុំផ្តល់ងារជាកិត្តិយស ការលើកទឹកចិត្ត ឬការចាត់តាំង ក្នុងមុខងារនានាដល់គោរមវន្ត ស្របតាមមាត្រា១៦ នៃព្រះរាជក្រឹត្យនេះ
- ជាដៃគូមួយរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញលើកកម្ពស់សេដ្ឋកិច្ច សកម្មភាពពាណិជ្ជកម្ម និងការវិនិយោគ ព្រមទាំងសកម្មភាពផ្សេងទៀត ដើម្បីផ្តល់ជាប្រយោជន៍ដល់សង្គមជាតិ
- អនុវត្តការងារផ្សេងទៀត ដែលកំណត់ដោយរាជរដ្ឋាភិបាល។

**មាត្រា១៥ .-**

និមិត្តសញ្ញានៃសមាគមឧកញ៉ាកម្ពុជាមានលក្ខណៈសម្គាល់ដូចខាងក្រោម៖

- រូបក្បាលហង្សពណ៌មាសរាងក្បាលស្រះ(ឧ)ពេញតួ
- ក្បាច់ភ្ញីទេសពណ៌មាសពត់ពេនជារាងស្រះ(ឧ)ពេញតួ
- ក្បាច់ភ្ញីទេសពណ៌មាសដែលមានរូបរាងដូចស្លឹកពោធិ៍ព័ទ្ធពីក្រៅជុំវិញស្រះ(ឧ)ពេញតួ
- ក្បាច់ត្របកឈូកធំពណ៌មាសដែលនៅចំកណ្តាលពីខាងក្រោមនៃស្រះ(ឧ) ពេញតួ និងក្បាច់ត្របកឈូកតូចៗពណ៌មាសជាច្រើនព័ទ្ធជុំវិញតាមរាងស្លឹកពោធិ៍
- ខ្សែបូពណ៌មាសទ្រពីក្រោមរូបស្លឹកពោធិ៍មានចារឹកអក្សរខ្មែរពណ៌មាស សមាគមឧកញ៉ាកម្ពុជា
- ក្បាច់ភ្ញីទេសពណ៌មាសទ្រពីក្រោមខ្សែបូ។

គំរូនិមិត្តសញ្ញានៃសមាគមឧកញ៉ាកម្ពុជា មានកំណត់ក្នុងឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៨

## សិទ្ធិ និងភាតព្វកិច្ចរបស់លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា

**មាត្រា១៦ .-**

លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា មានសិទ្ធិនិងកាតព្វកិច្ច ដូចខាងក្រោម៖

- ទទួលបាននូវការផ្តល់ងារជាកិត្តិយស ការលើកទឹកចិត្ត និងឯកសណ្ឋានផ្លូវការ ឬការចាត់តាំង ក្នុងមុខងារដែលមិនត្រូវបានហាមឃាត់ក្នុងព្រះរាជក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- អាចលើកសំណូមពរឬសំណើផ្សេងៗ តាមរយៈសមាគមឧកញ៉ាកម្ពុជា មករាជរដ្ឋាភិបាល ដើម្បីពិនិត្យនិងដោះស្រាយ
- ចូលរួមថែរក្សា ការពារវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ដ៏ល្អរបស់ជាតិ
- ចូលរួមចំណែកកសាងនិងអភិវឌ្ឍប្រទេសជាតិតាមការអំពាវនាវឬសំណូមពររបស់រាជរដ្ឋាភិបាល
- ចូលរួមលើកកម្ពស់ កិច្ចការសង្គម និងការងារមនុស្សធម៌ផ្សេងៗ
- ចូលរួមផ្តល់ព័ត៌មានដល់សមាគមឧកញ៉ាកម្ពុជាក្នុងការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះគោរមវន្ត។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



www.moj.gov.kh

**មាត្រា១៧ .-**

លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ត្រូវគោរពរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ព្រះរាជាណាចក្រកម្ពុជា ប្រកាន់ខ្ជាប់នូវសីលធម៌ល្អ ប្រកបមុខរបរស្របច្បាប់ និងចៀសវាងសកម្មភាពណាដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសនិងសេចក្ដីថ្លៃថ្នូររបស់គោរមងារឧកញ៉ា។

## ជំពូកទី៩
## ការបញ្ចប់គោរមងារឧកញ៉ា

**មាត្រា១៨ .-**

គោរមងារឧកញ៉ាអាចត្រូវបានបញ្ចប់ ក្នុងករណីណាមួយ ដូចខាងក្រោម៖

- គោរមវន្តសុំលាលែងពីគោរមងារឧកញ៉ាដោយស្ម័គ្រចិត្ត
- គោរមវន្តត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ
- គោរមវន្តត្រូវបានរកឃើញថាបានប្រព្រឹត្តល្មើសនឹងមាត្រា១៧ នៃព្រះរាជក្រឹត្យនេះ
- គោរមវន្តត្រូវបានរកឃើញថាសំណុំឯកសារស្នើសុំគោរមងារឧកញ៉ារបស់ខ្លួនមានការក្លែងបន្លំ។

បែបបទនិងនីតិវិធីនៃការបញ្ចប់គោរមងារឧកញ៉ា ត្រូវកំណត់ដោយអនុក្រឹត្យ។

ក្នុងករណីចាំបាច់ នាយករដ្ឋមន្ត្រីអាចលើកសំណើទូលថ្វាយព្រះមហាក្សត្រក្នុងការបញ្ចប់គោរមងារឧកញ៉ាតាមលំដាប់ថ្នាក់ណាមួយ។

## ជំពូកទី១០
## អន្តរប្បញ្ញត្តិ

**មាត្រា១៩ .-**

ព្រះរាជក្រឹត្យនេះមិនមានអានុភាពប្រតិសកម្មដល់គោរមងារឧកញ៉ាដែលគោរមវន្តទទួលបានមុនពេលព្រះរាជក្រឹត្យនេះចូលជាធរមានឡើយ។

គោរមវន្តទាំងអស់ត្រូវអនុវត្តសិទ្ធិ និងកាតព្វកិច្ច ដែលកំណត់ក្នុងព្រះរាជក្រឹត្យនេះ។

មន្ត្រីនគរបាលជាតិ និងយោធិន ដែលកំពុងបំពេញការងារតាមក្រសួង ស្ថាប័ននានារបស់រដ្ឋ ដែលទទួលបានគោរមងារឧកញ៉ាមុនព្រះរាជក្រឹត្យនេះចូលជាធរមាន ត្រូវស្នើសុំលាឈប់ប្រើប្រាស់គោរមងារឧកញ៉ា ឬលាឈប់ពីក្របខណ្ឌមន្ត្រីនគរបាលជាតិ និងយោធិន បន្ទាប់ពីព្រះរាជក្រឹត្យនេះចូលជាធរមាន។

បទប្បញ្ញត្តិក្នុងកថាខណ្ឌទី៣ខាងលើ មិនអនុវត្តចំពោះគោរមវន្តដែលមានចំណេះជំនាញពិសេសលើវិស័យណាមួយ ហើយមានការទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចជាតិឬអន្តរជាតិ។

## ជំពូកទី១១
## អវសានប្បញ្ញត្តិ

**មាត្រា២០ .-**

ព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ស្ដីពីគោរមងារឧកញ៉ា អនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៤ ស្ដីពីបែបបទនិងនីតិវិធីនៃការស្នើសុំនិងវាយ


www.moj.gov.kh

តម្លៃក្នុងការផ្តល់គោរមងារឧកញ៉ានិងការបញ្ចប់គោរមងារឧកញ៉ា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២១ .-**

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ អា ១០រោច ខែ អស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០២៤

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

រកត. ២៤១០ .១៣១២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**



www.moj.gov.kh

## ឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យលេខ ១៣០៩ ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០២៤
## ស្ដីពីគោរមងារឧកញ៉ា

# និមិត្តសញ្ញានៃសមាគមឧកញ៉ាកម្ពុជា

ក្បាច់ភ្ញីទេសពណ៌មាសពត់ពេនជារាងស្រះ (ឱ) ពេញតួ៖ តំណាងឱ្យវប្បធម៌ខ្មែរ និងភាពខ្ពង់ខ្ពស់ អង់អាច។



ប្រក្បាលហង្សពណ៌មាសរាងក្បាលស្រះ (ឱ) ពេញតួ៖ តំណាងឱ្យសភាវៈល្អថ្លៃថ្លា ភាពអង់អាច មោះមុត និងមេត្តាធម៌។



ក្បាច់ភ្ញីទេសពណ៌មាសដែលមានប្រឡាងដូចស្លឹកពោធិ៍ព័ទ្ធពីក្រៅជុំវិញស្រះ (ឱ) ពេញតួ៖ តំណាងឱ្យការប្រាស្រ័យទាក់ទង និងកិច្ចសហការក្នុងគ្រួសារឧកញ៉ាកម្ពុជាជួយដល់ប្រជាជនក្រីក្រ និងលើកកម្ពស់ឧត្តមភាពនៃគោរមងារឧកញ៉ានៅកម្ពុជា។





ក្បាច់ភ្ញីទេសពណ៌មាសទ្រក្រោមខ្សែបូ៖ តំណាងឱ្យសំឡេងរួម សកម្មភាពសប្បុរសធម៌ រួមនឹងការជួយលើកតម្កើងគុណតម្លៃដ៏ឧត្តុង្គឧត្តមនៃគោរមងារឧកញ៉ានៅកម្ពុជា។



ក្បាច់ត្របកឈូកធំពណ៌មាសដែលនៅចំកណ្ដាលពីខាងក្រោមនៃស្រះ (ឱ) ពេញតួ និងក្បាច់ត្របកឈូកតូចៗជាច្រើនព័ទ្ធជុំវិញតាមរាងស្លឹកពោធិ៍៖ តំណាងឱ្យភាពរុងរឿង និងភាពសុខដុមរមនានៃគ្រួសារឧកញ៉ាកម្ពុជា។



ខ្សែបូពណ៌មាសទ្រពីក្រោមរូបស្លឹកពោធិ៍មានចារឹកអក្សរខ្មែរពណ៌មាស សមាគមឧកញ៉ាកម្ពុជា៖ តំណាងឱ្យកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងការវិនិយោគយ៉ាងទូលំទូលាយពីសមាគមឧកញ៉ាកម្ពុជាក្នុងកម្រិតជាតិ និងអន្តរជាតិ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL